ការជំនុំជំរះក្តីរបស់អ្នកកាសែតឈ្មោះ Anik

ប្រវត្តិសាវតា

"ស៊ូលេន" (Suzland) គឺជាប្រទេសកោះមួយដែលមានប្រជាជនចំនួន ៤៣ សែននាក់។ ប្រទេសនេះធ្លាប់ឋិតក្រោមអាណានិគមអង់គ្លេសរហូតដល់បានឯករាជ្យនៅឆ្នាំ១៩៤៩។ Suzland បានរក្សាសិន្តិភាពរហូតដល់ទសវត្ស១៩៧0 ដែលមានចំបាំងផ្ទុះឡើងរវាងរដ្ឋពីធំៗនៃប្រទេស "ស៊ូលេន"ខាងជើង និងខាងត្បូង។ ខណៈនោះ Suzland ត្រូវបានរិះគន់យ៉ាងខ្លាំងពីសំណាក់សហគមន៍អន្តរជាតិក្នុងការខកខានមិនធ្វើសច្ចាប័នសន្ធិសញ្ញាសិទ្ធិមនុស្ស និងមិនការពារប្រជាជនរបស់ខ្លួនពីជំលោះផ្ទៃក្នុង។ នៅខែមិនាឆ្នាំ១៩៩១ មេដឹកនាំគណៈបក្សប្រឆាំង និងជាប្រជាជនខាងត្បូង ឈ្មោះ Dan Chian Kong នៃគណបក្សអំណាចប្រជាជន បានធ្វើរដ្ឋប្រហារ។ រដ្ឋប្រហារនេះបានផ្តួលរលំរដ្ឋភិបាលកំពុងកាន់អំណាច ហើយបន្តុបគណៈបក្សអំណាចប្រជាជនឡើងកាន់អំណាចជំនួសវិញ។ រដ្ឋប្រហារនេះបានទទួលនូវការគាំទ្រភាគច្រើនពីប្រជាជន។

Dan Chian Kong ត្រូវបានសហគមន៍ អន្តរជាតិស្នើអោយធ្វើសច្ចាប័នសន្ធិសញ្ញាអន្តរជាតិភ្លាមៗបន្ទាប់ពីបានកាន់តំណែងជានាយករដ្ឋមន្ត្រី ដែលរួមមានកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋ និងសិទ្ធិនយោបាយ កតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិសេដ្ឋកិច្ច សង្គម និងវប្បធម៌ ព្រមទាំងសន្ធិសញ្ញាប្រឆាំងទារុណកម្ម។ ទោះបីជាយ៉ាងនេះក្តី គណបក្សអំណាចប្រជាជនបានធ្វើការផ្លាស់ប្តូរជាច្រើនដូចជាការកែទំរង់ តុលាការ និងប្រព័ន្ធកាត់ក្តី។ ចៅក្រម និងព្រះរាជអាជ្ញាត្រូវបានដកតំណែង និងជំនួសដោយមន្ត្រីដែលតែងតាំងដោយ Dan Chian Kong ។ តួនាទីទាំងអស់នេះត្រូវបានតែងតាំងដល់អ្នកគាំទ្ររបស់គណបក្សអំណាចប្រជាជន ។

បើទោះបីជាមានការគាំទ្រជាច្រើនពីសំណាក់ជាតិ និងអន្តរជាតិលើរដ្ឋប្រហារនេះ ប្រជាប្រិយភាពរបស់ Dan Chian Kong បានចាប់ផ្តើមធ្លាក់ចុះ។ អ្នករិះគន់បានសំដែងនូវការព្រួយបារម្ភពីប្រព័ន្ធយុត្តិធម៌ ហើយបានចោទប្រកាន់នាយករដ្ឋមន្ត្រីពីបទលួចថវិកាជាតិ។ Dan Chian Kong បានឆ្លើយតបនឹងការរិះគន់តាមរយៈការប្រើប្រាស់ច្បាប់អាណានិគមចាស់ ដើម្បីផលចំណេញនយោបាយ។ ច្បាប់ចាស់ដែលបានអនុម័តដោយអង់គ្លេស ក្នុងកំឡុងពេលអណានិគមនេះ

មានដូចជា " បទព្រហ្មទណ្ឌបរិហារកេរ្តិ៍ " " ច្បាប់ប្រមាថកាតទាន " និងការប៉ះពាល់ដល់សន្តិសុខជាតិ " នៅមានសុពលភាពក្នុងប្រទេស Suzland នៅឡើយ។ Dan Chian Kong បានអនុវត្តនូវយុទ្ធនាការនេះពាសពេញប្រទេសក្នុងការប្តឹងអ្នកកាសែត អ្នកតស៊ូមតិដើម្បីការគោរពសិទ្ធិមនុស្ស និងអ្នករិះគន់រដ្ឋាភិបាលដ៏ទៃទៀត ដោយប្រើច្បាប់ចាស់ទាំងនេះ។

នៅថ្ងៃទី ០១ខែ មិថុនា ឆ្នាំ២០០៨ Dan Chian Kong បានបញ្ជាក់ថាខ្លួននឹងដាក់ចេញនូវបទល្មើសថ្មីមួយ " ការនិយាយក្លែងបង្ខូចប្រទេស Suzland " ដែលមានទោសពិន័យជាប់គុកចំនួន ៥ឆ្នាំ។ បទល្មើសនេះត្រូវបានដាក់បញ្ចូលទៅក្នុងផ្នែកទី ៩៣ នៃក្រមព្រហ្មទណ្ឌ ហើយមានប្រសិទ្ធិភាពនៅថ្ងៃទី ១៥ ខែមិថុនា ឆ្នាំ ២០០៨។

សាវតារករណី

Anik គឺជាអ្នកសារព័ត៌មានដ៏ល្បីឈ្មោះខាងរិះគន់មិនសំចៃលើរដ្ឋាភិបាល ជាពិសេសគឺរិះគន់ Dan Chian Kong ។ ពីមុននេះ នាងបានបោះផ្សាយរឿងប្រឌិតខ្លីៗ និងអត្ថបទជាច្រើនដែលពិភាក្សា ពីភាពវឹកវរនៃសេដ្ឋកិច្ច និងនយោបាយនាពេលបច្ចុប្បន្ន។ វិធីពិភាក្សាដោយត្រង់ៗ បានទាក់ទាញចំណាប់អារម្មណ៍អន្តរជាតិលើការងាររបស់នាង ព្រមទាំងបញ្ហាផ្ទៃក្នុងរបស់ Suzland ។ Anik ត្រូវបានផ្តន្ទាទោលពីបទព្រហ្មទ័ណ្ឌបង្ខូចកេរ្តិ៍ឈ្មោះបួនលើករួចទៅហើយ ហើយបានជាប់ពន្ធធនាគារចំនួនបីខែ បីលើក និងបង់ប្រាក់ពិន័យចំនួន $ 3500 ។ មិនតែប៉ុណ្ណោះ តុលាការមានអំណាចដាក់សាលក្រមអោយចុងចោទបង់ប្រាក់បន្ថែមលើការចាយវាយ ក្នុងការដកការផ្សព្វផ្សាយពាណិជ្ជកម្ម លើរាល់សារព័ត៌មាន ដើម្បីសុំទោសដើមបណ្តឹង។

អត្ថបទថ្មីមួយរបស់ Anik បានបោះពុម្ពផ្សាយនៅថ្ងៃទី ២0 ខែឧសភា ឆ្នាំ២០០៨ នៅលើសារព័ត៌មាន The Suzland Times ។ ក្នុងអត្ថបទនេះ Anik បានថ្លែងថា គណបក្សអំណាចប្រជាជន និងជាពិសេស Dan Chian Kong បានសំលាប់ប្រជាពលរដ្ឋភាគខាងត្បូងច្រើនជាង៥00 នាក់ក្នុងកំឡុងពេលធ្វើរដ្ឋប្រហារ ដែលនាំអោយ Dan Chian Kong បានឡើងកាន់អំណាច។ ក្នុងអត្ថបទនេះ Anik បានសរសេរថា:

" គ្មាននរណាម្នាក់នៅប្រទេស Suzland ហ៊ានរៀបរាប់ពីមរណភាពដ៏គួរអោយរន្ធត់និងអយុត្តិធម៌របស់បងប្អូនជនរួមជាតិយើងដែលកើតឡើងកាលពីឆ្នាំ ១៩៩១ ក្រោមកណ្តាប់ដៃរបស់ Dan Chian Kong នៃគណបក្សអំណាចប្រជាជននោះទេ ។ បងប្អូនខាងត្បូងជាង ៥00 នាក់បានបាត់បង់ជីវិតរបស់ពួកគេ ហើយរដ្ឋាភិបាលគួរតែត្រូវបានកាត់ទោស ចំពោះមរណភាពនេះ ។ ប៉ុន្តែតុលាការ ខ្ទះឯករាជ្យភាពក្នុងការធ្វើការស៊ើបអង្កេតដោយមិនលំអៀង ។ ឧក្រិដ្ឋជនទាំងនេះមិនអាចបន្តកាន់អំណាចទៀតទេ ខណៈដែលពួកគេប្រឡាក់ដោយឈាម ។ ឥឡូវ ពួកគេកំពុងតែលួចថវិការរបស់យើង ស្រដៀងគ្នានឹងការលួចជីវិតរបស់យើងកាលពីមុន ។

សារព័ត៌មាន Suzland Times ត្រូវបានផ្អាកមិនអោយដំណើរការនៅថ្ងៃទី ២៣ ខែឧសភា ចំនួន ៣0ថ្ងៃ ហើយរដ្ឋាភិបាលដែលមានភាគហ៊ុនធំក្នុងក្រុមហ៊ុនព័ត៌មាន Suzland Times បានដកហូតរាល់ការផ្សព្វផ្សាយពាណិជ្ជកម្មអត្ថបទនេះទាំងអស់ ។ មិនតែប៉ុណ្ណោះ សិទ្ធិជាអ្នកសារព័ត៌មានរបស់ Anik ត្រូវបានដកហូតផងដែរ ។ នេះបានន័យថារាល់អត្ថបទរបស់នាងក្រោយពីការដកហូតសិទ្ធិនេះ គឺខុសច្បាប់ ។

Anik ត្រូវបានគេចាប់ខ្លួន នៅថ្ងៃទី ២៥ ខែឧសភា ឆ្នាំ ២00៨ ។ ព្រះរាជអាជ្ញាចំណាយពេល ៤សប្តាហ៍ដើម្បីបញ្ចប់ការស៊ើបអង្កេត និង ចោទប្រកាន់ជាផ្លូវការលើ Anik នៅថ្ងៃទី ២៣ ខែមិថុនា ឆ្នាំ២00៨ ពីបទព្រហ្មទណ្ឌបង្ខូចកេរ្តិ៍ឈ្មោះនិងបង្ករុះបង្អាប់រដ្ឋាភិបាល Suzland ក្រោមច្បាប់ព្រហ្មទ័ណ្ឌមាត្រា៣២ ថ្នេក ៥៣ :

<u>មាត្រា៣២ បង្ខូចកេរ្តិ៍ឈ្មោះ</u>

១. បុគ្គលណាដែលបោះផ្សាយការបរិហាកេរ្តិ៍ដែលដឹងថាមិនពិតត្រូវជាប់ចោទពីបទបង្ខូចកេរ្តិ៍ឈ្មោះ និងត្រូវចាប់ពន្ធធានាគារចាប់ពី ៦ខែទៅ ២ឆ្នាំរួមទាំងបង់ប្រាក់ពិន័យមិនលើសពី១ពាន់ ដុល្លា ឬត្រូវទទួលពិន័យទាំងអស់ ។

២. បទល្មើសបង្ខូចកេរ្តិ៍ឈ្មោះនេះនឹងមិនមានសុពលភាពតាមកថាខ័ណ្ឌទី១ ករណីដែលការបោះពុម្ពផ្សាយនេះជាការពិត ហើយជាចាំបាច់ដើម្បីផលប្រយោជន៍សារធារណៈ ។

៩៣. ការបង្ខុះបង្ហាប់បុគ្គលសាធារណៈនៃប្រទេស Suzland នាយករដ្ឋមន្ត្រី និងស្ថាប័នតុលាការទាំងអស់

១. ការបង្ខុះបង្ហាប់បុគ្គលសាធារណៈនៃប្រទេស Suzland នាយករដ្ឋមន្ត្រី និងស្ថាប័នតុលាការទាំងអស់នឹងត្រូវដាក់ទោសជាប់ពន្ធធនាគារចំនួន៥ឆ្នាំ។

ការជំនុំជំរះក្តីរបស់ Anik ត្រូវបានកំណត់នៅថ្ងៃទី៥ ខែកក្កដា ឆ្នាំ២០០៨ នៅចំពោះតុលាការព្រហ្មទ័ណ្ឌប្រជាជន។ នាងត្រូវបានឃុំខ្លួនមុនពេលជំនុំជំរះក្តីចាប់តាំងពីថ្ងៃ២៥ ខែមិនាឆ្នាំ ២០០៨។ មិនមានការកោះហៅពីតុលាការនៅឡើយ។

របាយការណ៍ករណីនេះ ត្រូវបានទទួលការិះគន់យ៉ងខ្លាំងពីសំណាក់អន្តរជាតិ។ Dan Chian Kong បានមានប្រតិកម្មតបទៅវិញដោយបញ្ជាក់ពីឯករាជ្យភាព និងអធិបតេយ្យភាពរបស់ប្រទេស Suzland ។ នៅប្រទេស Suzland ភាសារជាផ្លូវការរបស់តុលាការគឺភាសារអង់គ្លេស។ Anik មិនចេះនិយាយភាសារអង់គ្លេស ហើយភាសារកំនើតរបស់នាងគឺ Suzland ដែលជាភាសារទីមួយរបស់ Suzland ។ ដើម្បីជំនះនូវផលលំបាកនេះ ការិយាល័យព្រះរាជអាជ្ញា នឹងផ្តល់សេវាកម្មបកប្រែដោយផ្ទាល់ដើម្បីបកប្រែក្នុងដំណើរការជំនុំជំរះជំនះក្តីសំរាប់ផលប្រយោជន៍ដល់ Anik ។ Anik ត្រូវបានគេផ្តល់ដំណើងថានាងត្រូវបង់ប្រាក់ $50 ក្នុងមួយថ្ងៃសំរាប់សេវាកម្មបកប្រែនេះ ហើយតំលៃនេះគឺស្មើនឹងប្រាក់ខែប្រចាំខែជាមធ្យមនៅប្រទេស Suzland ។ ទោះបីជាមានការសន្យាបែបនេះក៏ដោយ ការចោទប្រកាន់ជាផ្លូវការរបស់ Anik មិនទាន់ត្រូវបានបកប្រែជាភាសារអង់គ្លេសនៅឡើយ។ ការជំនុំជំរះក្តីរបស់ Anik នេះបានធ្វើអោយមានការពិភាក្សាជាសាធារណៈមិនចេះចប់មិនចេះហើយ។ មានមនុស្សជាច្រើននៅឈរពីមុខតុលាការដោយរួមទាំងមានចំណាប់អារម្មណ៍យ៉ាងខ្លាំងពីសំណាក់អន្តរជាតិ។ ក្នុងនោះក៏មានជឿថា នឹងមានក្រុមអន្តរជាតិគ្រោងធ្វើបាតុកម្មនៅពីមុខតុលាការផងដែរ។ ខណៈនេះ រដ្ឋាភិបាល និងកងកម្លាំងប៉ូលីសជាតិមិនទាន់ដាក់គំរោងការពារសន្តិសុខទប់ស្កាត់ហ្វូងមនុស្ស រឺការពារចុងចោទនៅឡើយ។

Anik បានជ្រើសរើសមេធាវីម្នាក់ដែលល្បីឈ្មោះក្នុងការការពារសកម្មជនរិះគន់រដ្ឋាភិបាល។ ប៉ុន្តែរាល់ការប្រជុំរបស់ Anik ជាមួយនឹងមេធាវីរបស់នាងតែងត្រូវបានឃ្លាំមើលដោយមន្ត្រីឆ្នាំគុក

បើទោះបីជាមានការតវ៉ាប្រឆាំងពីមេធាវីនាងក៏ដោយ។ ក្នុងនោះមេធាវីរបស់ Anik ត្រូវបានហាមឃាត់មិនអោយជួបនាងពីរលើកដោយហេតុផលសន្តិសុខ។

Anik គ្រោងនឹងទាមទារយុត្តិធម៌ដោយមិនទទួលនូវការចោទប្រកាន់ទាំងពីរបទល្មើសនោះឡើយ។ នាងនឹងបញ្ជាក់ថាអ្វីដែលនាងបោះពុម្ពផ្សាយជាការពិត និងដើម្បីផលប្រយោជន៍សាធារណៈជនដូចមានចែងក្នុងវគ្គ ៣២។ Anik ក៏ត្រូវបានប្តឹងដោយ Dan Chian Kong ទៅកាន់តុលាការស៊ីវិល ទាមទារសំណង $១០លាន ចំពោះអត្ថបទដដែល ដែលនាងចុះលើការសែត Suzland Times។